# ផែនការអនុវត្តការចាក់ថ្នាំបង្ការកូវីដ១៩ សម្រាប់ត្រីមាសទី៤

## □ អ្នកមិនបានចាក់ថ្នាំបង្ការ

◦ ការចាក់វ៉ាក់សាំងម៉ូឌើរណា(Moderna) និង ភីហ្វ័រ(Pfizer) នៅស្ថាប័នវេជ្ជសាស្ត្រដែលផ្តល់ឱ្យ*

* អ្នកដែលមិនបានចុះធានារ៉ាប់រងជាតិ គឺអាចទៅចាក់ថ្នាំនៅមណ្ឌលចាក់ថ្នាំបង្ការបាន

- អ្នកចង់ចាក់វ៉ាក់សាំង អាស្ត្រាហ្សេនីកា(AstraZeneca) ៖ អាចចាក់លើកទី១ (អាយុលើសពី ៣០ឆ្នាំ)

- ជេនសិន(Janssen) ៖ ជាទូទៅការចាក់វ៉ាក់សាំង សម្រាប់អាយុលើសពី ៥០ឆ្នាំ

*លោកអ្នកដែលចង់ចាក់វ៉ាក់សាំង ក្នុងចំណោមអ្នកដែលមានអាយុលើសពី៣០ឆ្នាំ និងពិបាកក្នុងការចាក់ថ្នាំ២ដង គួរទាក់ទងទៅកាន់មណ្ឌលសុខាភាពសាធារណៈ នឹងអាចចាក់ថ្នាំបង្ការភ្លាមៗបាន នៅតាមស្ថាប័នចាក់ថ្នាំបង្ការដែលបានកំណត់

## □ ការកែតម្រូវចន្លោះពេល ចាក់វ៉ាក់សាំង ម៉ូឌើរណា(Moderna) និង ភីហ្វ័រ(Pfizer)

◦ នៅសប្តាហ៍ទី២ ខែតុលា(ថ្ងៃទី១១ ខែតុលា~ថ្ងៃទី១៧ ខែតុលា)ត្រូវបានកែសម្រួលកាលវិភាគ ចាប់ផ្តើមពីអ្នកកក់នៃការចាក់ថ្នាំលើកទី២

- កាត់បន្ថយ ១សប្តាហ៍(៦សប្តាហ៍→៥សប្តាហ៍)៖ អ្នកដែលគ្រោងចាក់ថ្នាំបង្ការលើកទី២ ចាប់ពីសប្តាហ៍ទី២ ខែតុលា ដល់សប្តាហ៍ទី១ ខែវិច្ឆិកា (ថ្ងៃទី១១ ខែតុលា~ថ្ងៃទី៧ ខែវិច្ឆិកា)

- កាត់បន្ថយ ២សប្តាហ៍(៦សប្តាហ៍→៤សប្តាហ៍)៖ អ្នកដែលគ្រោងចាក់ថ្នាំបង្ការលើកទី២ ចាប់ពីសប្តាហ៍ទី២ ខែវិច្ឆិកា (ថ្ងៃទី៨ ខែវិច្ឆិកា~ ថ្ងៃទី១៤ ខែវិច្ឆិកា)

* ករណីពិបាកក្នុងការចាក់ថ្នាំ ទៅតាមការកែតម្រូវកាលបរិច្ឆេទ ដោយសារហេតុផលផ្ទាល់ខ្លួន ចាប់ពី(សុក្រ)ថ្ងៃទី១ ខែតុលា អ្នកអាចផ្លាស់ប្តូរ កាលវិភាគនៅគេហទំព័រ 예방접종예약누리집 (http://ncvr2.kdca.go.kr)បាន

◦ បន្ទាប់ពីខែតុលា អ្នកចាក់ថ្នាំលើកទី១ គឺការចាក់ថ្នាំលើកទី២ នៅចន្លោះ ៣សប្តាហ៍សម្រាប់ Pfizer និង៤សប្តាហ៍សម្រាប់ Moderna

## □ ការចាក់ថ្នាំបង្ការដល់កុមារ(Pfizer)

| គោលដៅ | **អាយុ១៦-១៧ឆ្នាំ** (ឆ្នាំកំណើត '០៤- ឆ្នាំកំណើត'០៥) | **អាយុ១២-១៥ឆ្នាំ**(ឆ្នាំកំណើត '០៤-ឆ្នាំកំណើត '០៥) |
|---|---|---|
| ការកក់ទុកជាមុន | (អង្គារ៍)ថ្ងៃទី៥ ខែតុលា - (សុក្រ)ថ្ងៃទី២៩ ខែតុលា | (ច័ន្ទ)ថ្ងៃទី១៨ ខែតុលា - (សុក្រ) ថ្ងៃទី១២ ខែវិច្ឆិកា |
| ថ្ងៃចាក់ថ្នាំ | (ច័ន្ទ)ថ្ងៃទី១៨ ខែតុលា - (សៅរ៍)ថ្ងៃទី១៣ ខែវិច្ឆិកា | (ច័ន្ទ)ថ្ងៃទី១ ខែវិច្ឆិកា - (សៅរ៍)ថ្ងៃទី២៧ ខែវិច្ឆិកា |

* ផ្អែកលើឆ្នាំកំណើត ក្នុងចំណោមសិស្សថ្នាក់ទី៦ នៃសាលាបឋមសិក្សា កុមារដែលមានឆ្នាំកំណើត ក្នុងឆ្នាំ២០១០ គឺត្រូវបានលើកលែងពីការចាក់ថ្នាំបង្ការ

◦ បន្ទាប់ពីធ្វើការកក់ជាបុគ្គល ការកក់ដោយសាមីខ្លួន ឬអ្នកតំណាង ត្រូវមានការទទួលយល់ព្រម ពីអាណាព្យាបាល(អ្នកតំណាងស្របច្បាប់) ក្នុងចាក់ថ្នាំបង្ការនៅស្ថាប័នវេជ្ជសាស្ត្រដែលបានចេញឱ្យ

## □ ការចាក់ថ្នាំបង្ការដល់ស្ត្រីមានផ្ទៃពោះ(សម្រេចចិត្តដោយខ្លួនឯង)

◦ ករណីអ្នកមានជំងឺប្រចាំកាយ ឬអ្នកមានផ្ទៃពោះដំបូង(តិចជាង១២សប្តាហ៍)មុនចាក់ថ្នាំ សូមណែនាំឱ្យទទួលពិនិត្យមើលស្ថានភាព របស់ម្តាយ និងទារកក្នុងផ្ទៃ ហើយនឹងធ្វើការចាក់ថ្នាំបង្ការ។

- អាចកក់ចាប់ពី(សុក្រ)ថ្ងៃទី៨ ខែតុលា, នៅពេលធ្វើការកក់សាមីខ្លួន សូមវាយបញ្ចូលការកក់ដោយខ្លួនឯង ដើម្បីអោយបុគ្គលិកពេទ្យ អាចទទួលដឹងព័ត៌មានស្ត្រីមានផ្ទៃពោះ*(ស្ថានភាពមានផ្ទៃពោះ, កាលបរិច្ឆេទកំណត់ផ្តល់កំណើតកូន)

* ប្រសិនបើ ព័ត៌មានស្ត្រីមានផ្ទៃពោះ មិនអាចត្រូវបានបញ្ចូលទេនោះ (ដូចជាការចាក់វ៉ាក់សាំងដែលនៅសេសសល់) នៅពេលចាក់ថ្នាំបង្ការនៅស្ថាប័នវេជ្ជសាស្ត្រ សូមប្រាប់ហេតុផលជាមុនទៅបុគ្គលិកពេទ្យ។

◦ ការអនុវត្តទៅតាមវ៉ាក់សាំងភីហ្វ័រ(Pfizer) និងម៉ូឌែរណា(Moderna) នៅស្ថាប័នវេជ្ជសាស្ត្រដែលបានចេញឱ្យ(ចាប់ពី(ចន្ទ័)ថ្ងៃទី១៨ខែតុលា~)

* ដើម្បីការពារដល់ស្ត្រីមានផ្ទៃពោះ សូមជម្រុញឱ្យសមាជិកគ្រួសារ ក៏ដូចជាមនុស្សនៅជុំវិញខ្លួនទាំងអស់ផងដែរ ដែលមានទំនាក់ទំនងជិតស្និតជាមួយស្ត្រីមានផ្ទៃពោះ ឱ្យទទួលការចាក់ថ្នាបង្ការ

## □ ការចាក់ថ្នាំបង្ការបន្ថែម(Booster Shot)

◦ ចំពោះអ្នកមានប្រព័ន្ធការពារភាពសុំាខ្សោយ* ការចាក់ថ្នាំបង្ការបន្ថែម បន្ទាប់ពីបញ្ចប់ការចាក់វ៉ាក់សាំងទូទៅរួច បាន២ខែកន្លងផុតទៅ សម្រាប់ការកក់ទុកមុន ចាប់ពី(ចន្ទ័)ថ្ងៃទី១៨ខែតុលា។ ការចាក់ថ្នាំ ចាប់ពី(ចន្ទ័)ថ្ងៃទី១ខែវិច្ឆិកា

* មនុស្សពេញវ័យ អាយុលើសពី១៨ឆ្នាំ ដែលពិបាកក្នុងការបង្កើតប្រព័ន្ធភាពសុំា ដូចជាជំងឺមហារីកគ្រាប់ឈាមធ្ងន់ធ្ងរ និងអ្នកជំងឺកំពុងព្យាបាលប្រព័ន្ធភាពសុំាដែលចុះខ្សោយ។ល។

◦ បុគ្គលិកពេទ្យ នៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ១៩, មន្ទីរពេទ្យថែទាំចាស់ជរា, បុគ្គលិកពេទ្យ•អ្នកជំងឺដែលចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ•មណ្ឌលថែទាំ និងបុគ្គលិកពេទ្យ នៃស្ថាប័នវេជ្ជសាស្ត្រដែលមានកម្រិតមន្ទីរពេទ្យឡើង គឺផ្តល់នៅស្ថាប័នវេជ្ជសាស្ត្រដោយខ្លួនឯង និងចុះចាក់ថ្នាំបង្ការដល់ទីកន្លែង

◦ ការកក់ទុកជាមុន សម្រាប់មនុស្សចាស់មានអាយុលើសពី៦០ឆ្នាំ និងក្រុមហានិភ័យខ្ពស់* ផ្សេងៗទៀត ចាប់ពី(អង្គារ៍)ថ្ងៃទី៥ខែតុលា។ ការចាក់ថ្នាំ គឺអនុវត្ត ចាប់ពី(ច័ន្ទ)ថ្ងៃទី២៥ខែតុលា (មានគាំទ្រសម្រាប់ការកក់ នៅសាលាភូមិ, ឃុំ, សង្កាត់, ខណ្ឌ ជាដើម)

* អ្នកដែលទទួលចាក់ថ្នាំបង្ការបន្ថែម(ចាប់ពីខែតុលា~)គឺមនុស្សវ័យចំណាស់ មានអាយុលើសពី៥០ឆ្នាំ ដែលបានចាប់ផ្តើមចាក់ថ្នាំបង្ការចាប់ពីខែមេសា, បុគ្គលិកពេទ្យ និងអ្នកចូលសម្រាកព្យាបាល•ប្រើប្រាស់ទីកន្លែងសម្រាកមនុស្សចាស់(កន្លែងសម្រាកមនុស្សចាស់ជរា•ផ្ទះរស់នៅរួមសម្រាប់មនុស្សចាស់•មើលថែថ្ងៃនិងយប់•មើលថែរយៈពេលខ្លី)

<បកប្រែដោយមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូរី ១៥៧៧- ១៣៦៦>